# បុព្វបទមង្គល ៣៨ ប្រការ

*កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់ព្រះឥរិយាបថ នៅវត្តជេតពន ជាអារាមអនាថបណ្ឌិកសេដ្ឋី មានបុរសម្នាក់បានពោលនៅក្នុងទីប្រជុំជនថា "មង្គលកិរិយានឹងកើតមានដល់យើង" ហើយចៀសចេញទៅ ។ មនុស្សទាំងឡាយបានស្តាប់ហើយមានចម្ងល់នឹងពាក្យនោះណាស់ ក៏នាំគ្នាសន្និដ្ឋានទៅតាមការយល់ឃើញរបស់ខ្លួនរៀងៗខ្លួន គឺអ្នកខ្លះថាៈ រូបដែលឃើញក្នុងពេលព្រឹកព្រហាម ដូចជារូបពណ៌ខៀវខ្ចី ១ ស្ត្រីមានផ្ទៃពោះ ១ ត្រីឆ្អិន ១ គោក្របាម ១ សំពត់សូត ១ បាយមធុបាយាស ១ ។ល។ ទាំងអស់នេះជាមង្គល ។ អ្នកខ្លះថាការបានស្តាប់ពាក្យល្អៗ ដូចជាពាក្យសម្បូណ៌ ១ ចម្រើន ១ បរិភោគ ១ ទំពារ ១។ល។ ទាំងអស់នេះទើបជាមង្គលពិតប្រាកដ ។ ពេលនោះមានមនុស្សម្នាក់រាងបែបគ្រាន់បើ បានក្រោកឡើងពោលឆ្គារដៃជើងថាបើគ្រាន់តែបានស្តាប់ពាក្យប៉ុណ្ណោះ ហើយយកមកចាត់ថាជាមង្គលនោះ ពិតជាខុសហើយ មង្គលពិតប្រាកដនោះបានដល់ការក្រោកពីដំណេកពីព្រលឹម ហើយចាប់ពាល់ផែនដី ១ ចាប់ពាល់ស្មៅដ៏ខៀវខ្ចី ១ ចាប់ពាល់សំពត់ដ៏ស្អាត ១ ចាប់ពាល់ត្រីឆ្អិន ១ ចាប់ពាល់មាសប្រាក់ព្រមទាំងគ្រឿងមាសប្រាក់ ១ ។ល។ ទាំងអស់នេះទើបហៅថាមង្គលពិតប្រាកដ ក្រៅពីនេះពុំមែនជាមង្គលទេ ។ នៅទីបំផុត មនុស្សនៅ*

ក្នុងទីប្រជុំជននោះត្រូវបានចែកជា ៣ ពួក គឺ ៖

ពួកទី ១ បានយល់ឃើញថាការមើលឃើញគឺជា "មង្គល"

ពួកទី ២ បានយល់ឃើញថាការបានស្ដាប់គឺជា "មង្គល"

ពួកទី ៣ បានយល់ឃើញថាការបានចាប់ពាល់គឺជា "មង្គល" ។ កាលបើដូច្នោះ ភាពសង្ស័យក៏កើតមានកាន់តែធំឡើង ៗ ជាលំដាប់ រហូតដល់ទេវលោក និងព្រហ្មលោក អស់រយៈពេល ១២ ឆ្នាំ ក៏នៅតែដោះស្រាយមិនចេញ ថាតើមង្គលពិតប្រាកដនោះគឺជាអ្វី ។

កាលណោះព្រះឥន្ទ្រាធិរាជទ្រង់មានព្រះតម្រិះថាៈ គ្មានអ្នកណាមួយអាចមានសមត្ថភាពដោះស្រាយរឿងនេះបានឡើយ ក្រៅតែពីព្រះសម្មាសម្ពុទ្ធបរមគ្រូមួយព្រះអង្គប៉ុណ្ណោះ ។ ដូច្នោះហើយ ទ្រង់ក៏នាំពួកទេវតាទាំងឡាយចុះមកឋានមនុស្សលោកទាំងរាត្រី ហើយចូលទៅគាល់ព្រះបរមសាស្ដាចារ្យក្នុងវត្តជេតពន ញុំាងទីនោះឲ្យមានពន្លឺចែងចាំងហាក់ដូចជាពេលថ្ងៃ ។ ទ្រង់បានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគដោយគោរពហើយ ទើបទូលសុំឲ្យព្រះអង្គជួយដោះស្រាយ នូវពាក្យថា "មង្គល" នោះ ។ សម្ដេចព្រះទ្រង់យស ប្រកបដោយព្រះបញ្ញាគុណ ព្រះមហាករុណាគុណ ព្រះវិសុទ្ធិគុណ ទ្រង់បានសម្ដែងអំពីមង្គលនោះប្រោសពួកទេវតាទាំងឡាយដែលមានព្រះឥន្ទ្រាធិរាជជាប្រធាន ដូចមានចែងក្នុងអត្ថបទខាងក្រោមនេះ ៖

# មង្គល ៣៨ ប្រការ

| | |
|---|---|
| **ពហូ ទេវា មនុស្សា ច** | **មង្គលានិ អចិន្តយុំ** |
| **អាកង្ខមានា សោត្ថានំ** | **ព្រូហិ មង្គលមុត្តមំ ។** |
| *ទេព្តាមនុស្សទាំងឡាយ* | *គិតខ្វល់ខ្វាយរកមង្គល* |
| *សូមទានព្រះទសពល* | *ប្រាប់មង្គលដ៏ឧត្តម ។* |
| **អសេវនា ច ពាលានំ** | **បណ្ឌិតានញ្ច សេវនា** |
| **បូជា ច បូជនីយានំ** | **ឯតម្មង្គលមុត្តមំ ។** |
| *ព្រះពុទ្ធទ្រង់ត្រាស់ថា* | *កុំស្នេហាពួកពាលធំ* |
| *គួរស្និទ្ធបណ្ឌិតសម* | *ហើយឲ្យខំធ្វើបូជា* |
| *ដល់លោកអ្នកដែលគួរ* | *ទើបនាំតួទៅសួគ៌ា* |
| *ទាំងបីនេះហៅថា* | *ជាមង្គលដ៏ឧត្តម ។* |
| **បដិរូបទេសវាសោ ច** | **បុព្វេ ច កតបុញ្ញតា** |
| **អត្តសម្មាបណិធិ ច** | **ឯតម្មង្គលមុត្តមំ ។** |
| *ការនៅក្នុងប្រទេស* | *ល្អវិសេសឬគួរសម* |
| *នឹងមានបុណ្យបានខំ* | *សាងសន្សំទុកពីមុន* |
| *ហើយតាំងខ្លួនត្រូវល្អ* | *តាមផ្លូវធម៌ប្រសើរលន់* |
| *ទាំងបីនេះជាបុណ្យ* | *ជាមង្គលដ៏ឧត្តម ។* |

ពាហុសច្ចញ្ច សិប្បញ្ច　　វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា　　ឯតម្មង្គលមុត្តមំ ។
ការបានស្តាប់ធម៌ច្រើន　　នឹងក្ររើនរៀនសីលថ្លៃ
និងបានរៀនវិន័យ　　ឆ្លាតវាងវៃជំនាញល្អ
សម្តែងសុចរិត　　សុភាសិតតាមផ្លូវធម៌
ទាំងបួនយ៉ាងនេះក៏　　ជាមង្គលដ៏ឧត្តម ។
មាតាបតុឧបដ្ឋានំ　　បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា　　ឯតម្មង្គលមុត្តមំ ។
បំរើអ្នកមាតា　　និងបិតាមានគុណធំ
សង្គ្រោះបុត្រភិរម្យ　　និងឧបត្ថមដល់ភរិយា
ធ្វើកិច្ចការអ្វី ៗ　　ខំឃ្មាតខ្មីមិនចោលការ
ទាំងបួននេះហៅថា　　ជាមង្គលដ៏ឧត្តម ។
ទានញ្ច ធម្មចរិយា ច　　ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ　　ឯតម្មង្គលមុត្តមំ ។
ការឲ្យវត្ថុទាន　　ធម៌ក៏បានប្រព្រឹត្តមាំ
សង្គ្រោះញាតិតូចធំ　　តាមគួរសមទោះជិតឆ្ងាយ
កិច្ចការណាឥតទោស　　ឬមិនខុសក៏ខ្វល់ខ្វាយ
ទាំងបួនដែលអធិប្បាយ　　ជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**

**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។**

*ការលះវាចាបាប សង្រួមភាពកាយរឿយៗ*

*ប្រយ័ត្នមិនធ្វេសទេឡើយ មិនហ៊ានផឹកទឹកស្រវឹង*

*ធម៌អាថ៌ផងទាំងឡាយ មិនមាក់ងាយប្រមាថខឹង*

*ទាំងបីយ៉ាងនេះសឹង ជាមង្គលដ៏ឧត្តម ។*

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។**

*សេចក្ដីគារវៈ ដល់លោកអ្នកដែលគួរផង*

*បន្ទាបខ្លួនឥតឆ្គង ព្រមទាំងមានក្ដីសន្ដោស*

*និងមានកតញ្ញូ ចេះស្ដាប់ធម៌នៃសប្បុរស*

*ទាំង ៥ នេះចំពោះ ជាមង្គលដ៏ឧត្តម ។*

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**

**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។**

*សេចក្ដីអត់សង្កត់ ធន់អំណត់មិនញាប់ញ័រ*

*ជាអ្នកមានចិត្តល្អ គេប្រដៅបានដោយងាយ*

*កាលឃើញពួកសមណៈ គួរសួរធម៌យ៉ាងរីករាយ*

*ទាំងបួនដែលអធិប្បាយ ជាមង្គលដ៏ឧត្តម ។*

**តបោ ច ព្រហ្មចរិយញ្ច　　អរិយសច្ចាន ទស្សនំ**
**និព្វានសច្ឆិកិរិយា ច　　ឯតម្មង្គលមុត្តមំ ។**

*ព្យាយាមដុតកិលេស　　ធម៌វិសេសប្រសើរក្រៃ*
*ប្រព្រឹត្តល្អប្រពៃ　　ឃើញអរិយសច្ច ៤*
*និងធ្វើព្រះនិព្វាន　　ឲ្យច្បាស់បានយ៉ាងមាំមួន*
*អ្នកធ្វើកិច្ចទាំង ៤　　ជាមង្គលដ៏ឧត្តម ។*

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ　　យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ　　ឯតម្មង្គលមុត្តមំ ។**

*ចិត្តនៃបុគ្គលណា　　មិនជ្រួលមិនញាប់ញ័រ*
*តាមលោកធម៌ទាំង ៨　　ជាចិត្តមានអធ្យោក*
*មិនសោយសោកប្រាប់ធូលី　　ជាចិត្តក្សេមពេញទី*
*ទាំង ៤ យ៉ាងនេះក៏　　ជាមង្គលដ៏ឧត្តម ។*

**ឯតាទិសានិ កត្វាន　　សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ　　តន្តេសំ មង្គលមុត្តមន្តិ ។**

*មនុស្ស ឬ ទេវតា　　ពួកឯណាមានកុសល*
*បានធ្វើនូវមង្គល　　ព្រះទសពលទ្រង់សម្តែង*
*ពួកនោះមិនថយថោក　　ខ្ពស់ក្នុងលោកឥតថ្លឹងថ្លែង*
*ហើយបានសុខជាក់ស្តែង　　ប្រាកដក្នុងទីទាំងពួង ៕*